ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ: ០១៣ ដនសប្រ.ក/និ.ក

# ប្រកាស
## ស្តីពី
## បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



អាសយដ្ឋាន: ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះកំណត់អំពីបែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ និងការផ្តល់លិខិតបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងគោលបំណងដើម្បីអនុវត្តអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់។

**ប្រការ២._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសំណង់ឬការងារ ស្ថិតក្រោមសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់របស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់។

**ប្រការ៣._**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ការងារសាងសង់** សំដៅដល់ការងារដី ការងារសាងសង់សំណង់ថ្មី ការងារកែប្រែ និងការដំឡើង។

២- **ការងារកែប្រែ** សំដៅដល់ការផ្លាស់ប្តូរមុខងារទ្រង់ទ្រាយទាំងស្រុងឬផ្នែកណាមួយនៃសំណង់។

៣- **គម្រោងអភិវឌ្ឍន៍អចលនវត្ថុ** សំដៅដល់គម្រោងអភិវឌ្ឍបុរី គម្រោងអភិវឌ្ឍអគារសហកម្មសិទ្ធិ ឬគម្រោងសាងសង់ដទៃទៀត លើកលែងតែគម្រោងសាងសង់លំនៅឋានផ្ទាល់ខ្លួន គម្រោងសាងសង់រោងចក្រក្នុងដីសម្បទានសេដ្ឋកិច្ច និងគម្រោងសាងសង់រោងសិប្បកម្មឬរោងចក្រសម្រាប់គោលដៅកសិកម្មក្នុងតំបន់កសិកម្ម។

៤- **ច្រកចេញចូលតែមួយ** សំដៅដល់ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៥- **តំណាងស្របច្បាប់របស់នីតិបុគ្គល** សំដៅដល់ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន អគ្គនាយកក្រុមហ៊ុន ឬនាយកក្រុមហ៊ុន ដែលមានគោត្តនាមនិងនាមត្រូវបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬភ្នាក់ងារតំណាងរបស់ក្រុមហ៊ុនសញ្ជាតិបរទេសដែលបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ឬប្រធានឬនាយកប្រតិបត្តិដែលមានគោត្តនាមនិងនាមត្រូវបានចែងនៅក្នុងលក្ខន្តិកៈឬអនុស្សរណៈរបស់អង្គការឬសមាគម ឬអ្នកតំណាងអង្គការឬសមាគម ឬប្រធានឬ

អ្នកតំណាងគណបក្សនយោបាយ ឬរូបវន្តបុគ្គលដទៃទៀតដែលមានគោត្តនាមនិងនាមត្រូវបានចែងនៅក្នុងប្រកាសឬលិខិតបទដ្ឋានស្តីពីការចុះបញ្ជីឬការទទួលស្គាល់នីតិបុគ្គលនោះ។

៦- **ម្ចាស់សំណង់** សំដៅដល់កម្មសិទ្ធិករនៃសំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ដែលគ្រោងឬបានសាងសង់នៅលើដីរបស់ខ្លួនផ្ទាល់ឬនៅលើដីរបស់អ្នកដទៃដោយមានការអនុញ្ញាតពីម្ចាស់ដី ឬអ្នកជួលអចិន្ត្រៃយ៍ដែលបានសាងសង់លើដីរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍។

៧- **លិខិតបញ្ជាក់ព័ត៌មានសុរិយោដី** សំដៅដល់ឯកសារដែលផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដែលមានបង្ហាញទីតាំងក្បាលដីនិងព័ត៌មានផ្សេងៗនៃក្បាលដី មានជាអាទិ៍ ប្រភេទ ស្ថានភាពគតិយុត្ត លក្ខណៈរូបនិងបន្ទុកនៃក្បាលដី ដោយផ្អែកលើឯកសារនិងសៀវភៅគោលបញ្ជីដីធ្លី។

៨- **សលាកបត្រក្បាលដី** សំដៅដល់ឯកសារផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដែលមានបង្ហាញប្លង់ដីឡូត៍ ប្លង់តំបន់ កម្មសិទ្ធិករនៃដី ទីតាំងនៃដី ទំហំដី និយាមកាចំណុចព្រំដី ប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី ស្ថានភាពនៃសំណង់ក្នុងនិងជុំវិញទីតាំងដី និងរូបថតបង្ហាញស្ថានភាពនៃដីឡូត៍។

៩- **អគ្គនាយកដ្ឋានជំនាញ** សំដៅដល់អគ្គនាយកដ្ឋានសំណង់ និងអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

១០- **ឯកសារបញ្ជាក់អំពីការកាន់កាប់ដីស្របច្បាប់** សំដៅដល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ បណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង វិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ ភតិសន្យាអចលនវត្ថុ ឬគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល។ ក្នុងករណីម្ចាស់សំណង់មិនមែនជាម្ចាស់ដី ត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីម្ចាស់ដី។

១១- **ឯកសារបញ្ជាក់អត្តសញ្ញាណម្ចាស់សំណង់** សំដៅដល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន ប្រកាសស្តីពីការចុះបញ្ជីសមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អនុស្សរណៈរបស់អង្គការឬសមាគមមិនមែនរដ្ឋាភិបាលបរទេសនិងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឬប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ។

## ជំពូកទី២
## បែបបទនៃការផ្តល់លិខិតអនុញ្ញាតសាងសង់

**ប្រការ៤._**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់មានដូចខាងក្រោម៖

| | |
|---|---|
| ១- ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ | ចំនួន១ ច្បាប់ |
| ២- ឯកសារបញ្ជាក់អត្តសញ្ញាណម្ចាស់សំណង់(ថតចម្លង) | ចំនួន២ ច្បាប់ |
| ៣- ឯកសារបញ្ជាក់ការកាន់កាប់ដីស្របច្បាប់(ថតចម្លង) | ចំនួន២ ច្បាប់ |
| ៤- សលាកបត្រក្បាលដី | ចំនួន២ ច្បាប់ |
| ៥- លិខិតបញ្ជាក់ព័ត៌មានសុរិយោដី | ចំនួន២ ច្បាប់ |
| ៦- ប្លង់ស្ថាបត្យកម្ម | ចំនួន៥ ច្បាប់ |
| ៧- របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម | ចំនួន៥ ច្បាប់ |
| ៨- លិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់ស្ថាបត្យកម្ម | ចំនួន៥ ច្បាប់ |

ក្នុងករណីការស្នើសុំលិខិតអនុញ្ញាតសាងសង់ដើម្បីអនុវត្តការងារកែប្រែ សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវភ្ជាប់មកជាមួយនូវប្លង់សម្រង់តាមការសាងសង់ជាក់ស្តែងផ្នែកស្ថាបត្យកម្មចំនួន២ (ពីរ)ច្បាប់។

ក្នុងករណីម្ចាស់សំណង់ជានីតិបុគ្គល ឯកសារបញ្ជាក់អត្តសញ្ញាណម្ចាស់សំណង់ ត្រូវមានភ្ជាប់មកជាមួយនូវលក្ខន្តិកៈរបស់នីតិបុគ្គលនោះ ចំនួន២(ពីរ)ច្បាប់ លើកលែងករណីសមាគមឬអង្គការមិនមែនរដ្ឋាភិបាលបរទេស។

ម្ចាស់សំណង់ត្រូវប្រគល់ប្លង់ស្ថាបត្យកម្មនិងសេចក្តីណែនាំបច្ចេកទេសផ្នែកស្ថាបត្យកម្មជាឯកសាររឹងនិងជាឯកសារទម្រង់ឌីជីថលជូនច្រកចេញចូលតែមួយ។

រាល់ប្លង់ស្ថាបត្យកម្ម ត្រូវភ្ជាប់មកជាមួយនូវសេចក្តីណែនាំបច្ចេកទេសផ្នែកស្ថាបត្យកម្ម។

គំរូទម្រង់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ។

គំរូទម្រង់សលាកបត្រក្បាលដី ជាឧបសម្ព័ន្ធ២នៃប្រកាសនេះ។

គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់សម្រាប់នីតិបុគ្គល ជាឧបសម្ព័ន្ធ៣នៃប្រកាសនេះ។

គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់សម្រាប់រូបវន្តបុគ្គល ជាឧបសម្ព័ន្ធ៤នៃប្រកាសនេះ។

**ប្រការ៥._**

ម្ចាស់សំណង់ត្រូវផ្តិតស្នាមមេដៃស្តាំឬចុះហត្ថលេខាដោយផ្ទាល់លើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់។

ក្នុងករណីម្ចាស់សំណង់ជានីតិបុគ្គល ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវមានស្នាមមេដៃស្តាំឬហត្ថលេខា គោត្តនាមនិងនាមរបស់តំណាងស្របច្បាប់ និងត្រារបស់នីតិបុគ្គលនោះ។ តំណាងស្របច្បាប់របស់នីតិបុគ្គល ត្រូវផ្តិតស្នាមមេដៃស្តាំឬចុះហត្ថលេខាដោយផ្ទាល់លើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់។

ក្នុងករណីនីតិបុគ្គលចាត់តាំងតំណាងផ្សេងទៀតដើម្បីបំពេញបែបបទស្នើសុំលិខិតអនុញ្ញាតសាងសង់ សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវភ្ជាប់មកជាមួយនូវលិខិតប្រគល់សិទ្ធិរបស់នីតិបុគ្គលនោះដោយមានការបញ្ជាក់ពីសារការី។

គំរូទម្រង់លិខិតប្រគល់សិទ្ធិធ្វើជាអ្នកតំណាងរបស់នីតិបុគ្គល ជាឧបសម្ព័ន្ធ៥នៃប្រកាសនេះ។

**ប្រការ៦._**

រាល់ឯកសារនៅក្នុងសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើជាភាសាខ្មែរ។ រាល់ឯកសារជាភាសាបរទេស ត្រូវបកប្រែជាភាសាខ្មែរដោយមានការបញ្ជាក់ពីសារការី។

សេចក្តីណែនាំបច្ចេកទេសផ្នែកស្ថាបត្យកម្ម អាចធ្វើជាភាសាអង់គ្លេស។

រាល់ឯកសារថតចម្លងត្រូវធ្វើនីត្យានុកូលកម្មដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ ឬដោយសារការី លើកលែងតែវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

## ជំពូកទី៣

## បរិបទនៃការផ្តល់លិខិតអនុញ្ញាតសាងសង់

**ប្រការ៧._**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវយកទៅដាក់នៅច្រកចេញចូលតែមួយ។

ច្រកចេញចូលតែមួយត្រូវត្រួតពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់នៅក្នុងថ្ងៃដាក់ពាក្យស្នើសុំ។

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃដោយអគ្គនាយកដ្ឋានជំនាញចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៨._**

ក្នុងករណីសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់មានលក្ខណៈគ្រប់គ្រាន់តាមតារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ច្រកចេញចូលតែមួយត្រូវអនុវត្តដូចខាងក្រោម៖

១- បំពេញលើតារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់។

២- ចុះលេខនិងកាលបរិច្ឆេទចូលក្នុងសៀវភៅចុះលេខចូលរបស់ច្រកចេញចូលតែមួយ និងចម្លងលេខនិងកាលបរិច្ឆេទលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់។

៣- បោះត្រាចូលរបស់ច្រកចេញចូលតែមួយនៅលើរាល់ឯកសារនៅក្នុងសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ចំនួន១(មួយ)ច្បាប់សម្រាប់ជូនទៅម្ចាស់សំណង់។

៤- រៀបចំបង្កាន់ដៃទទួលពាក្យស្នើសុំដោយមានលេខនិងកាលបរិច្ឆេទចូល និងហត្ថលេខារបស់មន្ត្រីទទួលបន្ទុក។

៥- រៀបចំនិងប្រគល់បង្កាន់ដៃបង់ប្រាក់សេវាពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់។

៦- ប្រគល់ច្បាប់ដើមនៃបង្កាន់ដៃទទួលពាក្យស្នើសុំដែលមានចុះលេខនិងកាលបរិច្ឆេទនិងសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ដែលមានបោះត្រាជូនទៅម្ចាស់សំណង់នៅក្នុងថ្ងៃពិនិត្យសំណុំឯកសារស្នើសុំនោះ បន្ទាប់ពីបង់កម្រៃសេវាពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់រួច។

**ប្រការ៩**._

ក្នុងករណីពិនិត្យឃើញថា សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់មានលក្ខណៈមិនគ្រប់គ្រាន់ មន្ត្រីច្រកចេញចូលតែមួយត្រូវអនុវត្តដូចខាងក្រោម៖

១- បំពេញលើតារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់អំពីការខ្វះខាតឯកសារឬភាពមិនត្រឹមត្រូវផ្នែកទម្រង់នៃឯកសារ។

២- ចុះកាលបរិច្ឆេទ ហត្ថលេខា និងគោត្តនាមនិងនាមរបស់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យសំណុំឯកសារលើតារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំដែលបំពេញរួច។

៣- ប្រគល់សំណុំឯកសារស្នើសុំនិងតារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំដែលបានបំពេញ ចុះកាលបរិច្ឆេទ ហត្ថលេខា និងគោត្តនាមនិងនាមរបស់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យសំណុំឯកសាររួច ជូនទៅម្ចាស់សំណង់ឬអ្នកតំណាងក្នុងថ្ងៃពិនិត្យសំណុំឯកសារស្នើសុំនោះ។

**ប្រការ១០**._

ការពិនិត្យនិងសម្រេចលើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ មានរយៈពេលយ៉ាងយូរ ៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលច្រកចេញចូលតែមួយចេញបង្កាន់ដៃទទួលពាក្យស្នើសុំតាមបរិបថដូចខាងក្រោម៖

១- ច្រកចេញចូលតែមួយ ត្រូវបញ្ជូនសំណុំឯកសារស្នើសុំទៅអគ្គនាយកដ្ឋានសំណង់ និងអគ្គ-នាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ ដើម្បីពិនិត្យនិងផ្តល់យោបល់។

២- អគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ ដែលមាននាយកដ្ឋានអភិរក្សសុរិយោដីជាសេនាធិការ មានរយៈពេលយ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំពីច្រកចេញចូលតែមួយ ដើម្បីពិនិត្យសំណុំឯកសារស្នើសុំនិងផ្ទៀងផ្ទាត់ព័ត៌មានក្បាលដីដែលផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងធ្វើ

របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មានក្បាលដី និងបញ្ជូនរបាយការណ៍នេះទៅច្រកចេញចូលតែមួយ។

៣- អគ្គនាយកដ្ឋានសំណង់ដែលមាននាយកដ្ឋានសិក្សាគម្រោងប្លង់ជាសេនាធិការ មានរយៈពេលយ៉ាងយូរ២៥(ម្ភៃប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំពីច្រកចេញចូលតែមួយ ដើម្បីពិនិត្យសំណុំឯកសារស្នើសុំ ធ្វើរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងវាយតម្លៃគម្រោងប្លង់ស្ថាបត្យកម្ម និងបញ្ជូនរបាយការណ៍នោះទៅច្រកចេញចូលតែមួយ។

៤- ច្រកចេញចូលតែមួយ ត្រូវដាក់របាយការណ៍ស្តីពីការត្រួតពិនិត្យនិងវាយតម្លៃគម្រោងប្លង់ស្ថាបត្យកម្មនិងរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មានក្បាលដីឆ្លងថ្នាក់ដឹកនាំក្រសួងតាមឋានានុក្រមដើម្បីទទួលមតិយោបល់និងការសម្រេច ក្នុងរយៈពេលយ៉ាងយូរ១(មួយ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារពីអគ្គនាយកដ្ឋានជំនាញ និងរៀបចំនិងប្រគល់បង្កាន់ដៃបង់ប្រាក់សេវាផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្លូវការក្នុងករណីបើមាន។

៥- អគ្គនាយកដ្ឋានរដ្ឋបាលដែលមាននាយកដ្ឋានរដ្ឋបាលជាសេនាធិការ ត្រូវចាត់ចែងចុះលេខកាលបរិច្ឆេទ និងបោះត្រាលើលិខិតអនុញ្ញាតសាងសង់ និងប្លង់អនុញ្ញាត រួចប្រគល់ជូនម្ចាស់សំណង់ឬអ្នកតំណាងតាមរយៈច្រកចេញចូលតែមួយ និងអគ្គនាយកដ្ឋានសំណង់ដើម្បីតម្កល់ទុកក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានការសម្រេចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ១១.**_

ក្នុងករណីចាំបាច់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចចាត់មន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះត្រួតពិនិត្យទីតាំងជាក់ស្តែងនៃគម្រោងសាងសង់។ មន្ត្រីត្រួតពិនិត្យសំណង់ត្រូវធ្វើកំណត់ហេតុនិងរបាយការណ៍ស្តីពីការចុះត្រួតពិនិត្យទីតាំងស្នើសុំសាងសង់ ក្នុងរយៈពេលយ៉ាងយូរ៣(បី)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃត្រួតពិនិត្យ។ រយៈពេលនៃការចុះត្រួតពិនិត្យ ធ្វើកំណត់ហេតុ និងរបាយការណ៍ស្តីពីការចុះត្រួតពិនិត្យទីតាំងស្នើសុំសាងសង់ ត្រូវរាប់បញ្ចូលក្នុងរយៈពេលនៃការសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់។

**ប្រការ១២.**_

ក្នុងករណីអគ្គនាយកដ្ឋានជំនាញពិនិត្យឃើញថា សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់តម្រូវឱ្យមានការកែតម្រូវឬបំពេញបន្ថែម អគ្គនាយកដ្ឋានជំនាញ ត្រូវធ្វើដីកាបញ្ជូនសំណុំឯកសារស្នើសុំមកច្រកចេញចូលតែមួយវិញ ដោយត្រូវបង្ហាញរាល់ចំណុចដែលត្រូវកែតម្រូវឬបំពេញបន្ថែមទាំងនោះ ក្នុងរយៈពេលយ៉ាងយូរ១២(ដប់ពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ពីច្រកចេញចូលតែមួយ។

ក្នុងករណីគម្រោងសាងសង់ បានចាប់ផ្តើមដំណើរការមុនការផ្តល់លិខិតអនុញ្ញាតសាងសង់ សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវបំពេញបន្ថែមនូវរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងវាយតម្លៃការងារសាងសង់ចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងច្បាប់ចម្លងនៃបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ចេញដោយមន្ត្រីអធិការកិច្ចសំណង់។

ច្រកចេញចូលតែមួយ ត្រូវធ្វើលិខិតជូនដំណឹងស្តីពីការកែតម្រូវឬបំពេញបន្ថែមសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ និងអញ្ជើញម្ចាស់សំណង់ឬអ្នកតំណាងមកទទួលយកលិខិតជូនដំណឹងនោះ ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

រយៈពេលនៃការកែតម្រូវឬបំពេញបន្ថែមសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ មិនរាប់បញ្ចូលក្នុងរយៈពេលនៃការពិនិត្យនិងសម្រេចផ្តល់លិខិតអនុញ្ញាតសាងសង់ឡើយ។

ក្នុងករណីមានការកែតម្រូវឬបំពេញបន្ថែមសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ រយៈពេលនៃការពិនិត្យនិងសម្រេចផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវចាប់រាប់ជាថ្មីឡើងវិញគិតចាប់ពីថ្ងៃច្រកចេញចូលតែមួយចេញបង្កាន់ដៃទទួលសំណុំឯកសារដែលបានកែតម្រូវឬបំពេញបន្ថែមនោះ។

គំរូទម្រង់លិខិតជូនដំណឹងស្តីពីការកែតម្រូវឬបំពេញបន្ថែមសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ជាឧបសម្ព័ន្ធ៦នៃប្រកាសនេះ។

**ប្រការ១៣._**

ក្នុងករណីអគ្គនាយកដ្ឋានជំនាញពិនិត្យឃើញថា ការស្នើសុំលិខិតអនុញ្ញាតសាងសង់មិនអនុលោមតាមបទប្បញ្ញត្តិជាធរមាន និងមិនអាចកែតម្រូវឬបំពេញបន្ថែមបាន អគ្គនាយកដ្ឋានពាក់ព័ន្ធនិងច្រកចេញចូលតែមួយត្រូវអនុវត្តតាមបរិបថដូចខាងក្រោម៖

១- អគ្គនាយកដ្ឋានជំនាញមានរយៈពេលយ៉ាងយូរ២៥(ម្ភៃប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំពីច្រកចេញចូលតែមួយ ដើម្បីធ្វើរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងវាយតម្លៃគម្រោងប្លង់ស្ថាបត្យកម្ម ឬរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មានក្បាលដី និងបញ្ជូនរបាយការណ៍នោះទៅច្រកចេញចូលតែមួយ។

២- ច្រកចេញចូលតែមួយ ត្រូវដាក់របាយការណ៍ស្តីពីការត្រួតពិនិត្យនិងវាយតម្លៃគម្រោងប្លង់ស្ថាបត្យកម្ម និង/ឬរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មានក្បាលដី ឆ្លងថ្នាក់ដឹកនាំក្រសួងតាមឋានានុក្រមដើម្បីទទួលមតិយោបល់និងការសម្រេច ក្នុងរយៈពេលយ៉ាងយូរ១(មួយ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារពីអគ្គនាយកដ្ឋានជំនាញ។

៣- អគ្គនាយកដ្ឋានរដ្ឋបាល ដែលមាននាយកដ្ឋានរដ្ឋបាលជាសេនាធិការ ត្រូវចាត់ចែងចុះលេខកាលបរិច្ឆេទ និងបោះត្រាលើលិខិតជូនដំណឹងស្តីពីការបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់ រួចប្រគល់ជូនម្ចាស់សំណង់ឬអ្នកតំណាងតាមរយៈច្រកចេញចូលតែមួយទាំងលិខិតជូនដំណឹង

ទាំងសំណុំឯកសារស្នើសុំ ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានការសម្រេចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

គំរូទម្រង់លិខិតជូនដំណឹងស្តីពីការបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់ ជាឧបសម្ព័ន្ធ៧នៃប្រកាសនេះ។

## ជំពូកទី៤
## បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ សម្រាប់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ

**ប្រការ១៤._**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ដូចមានចែងក្នុងជំពូកទី២នៃប្រកាសនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់នៅក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ និងត្រូវបន្ថែមលិខិតអនុញ្ញាតអភិវឌ្ឍដីនិងប្លង់អភិវឌ្ឍដីផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ១៥._**

លិខិតអនុញ្ញាតសាងសង់អាចផ្តល់តាមសំណើរបស់ម្ចាស់សំណង់ តាមដំណាក់កាលស្របតាមផែនការដូចមានកំណត់ក្នុងលិខិតអនុញ្ញាតអភិវឌ្ឍដី។

**ប្រការ១៦._**

បរិបថនៃការពិនិត្យនិងសម្រេចលើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ដូចមានចែងក្នុងជំពូកទី៣នៃប្រកាសនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ។

## ជំពូកទី៥
## បែបបទនិងបរិបថនៃការបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់

**ប្រការ១៧._**

ម្ចាស់សំណង់ឬអ្នកតំណាង ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់នៅច្រកចេញចូលតែមួយ ក្នុងរយៈពេល៣០( សាមសិប)ថ្ងៃមុនកាលបរិច្ឆេទផុតសុពលភាពនៃលិខិតអនុញ្ញាតសាងសង់។

ក្នុងករណីមានការកែប្រែឯកសារណាមួយនៃសំណុំឯកសារដែលទទួលបានលិខិតអនុញ្ញាតសាងសង់លើកដំបូង សំណុំឯកសារស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ ត្រូវមានបន្ថែមឯកសារថ្មីស្របតាមការកែប្រែនោះ។

គំរូទម្រង់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ ជាឧបសម្ព័ន្ធ៨នៃប្រកាសនេះ។

គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់សម្រាប់នីតិបុគ្គល ជាឧបសម្ព័ន្ធ៩នៃប្រកាសនេះ។

គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់សម្រាប់រូបវន្តបុគ្គល ជាឧបសម្ព័ន្ធ១០នៃប្រកាសនេះ។

**ប្រការ១៨._**

បរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ ដូចមានចែងក្នុងជំពូកទី៣នៃប្រកាសនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការផ្តល់លិខិតបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់។

លិខិតបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ អាចចេញបានតែមួយដងគត់។

## ជំពូកទី៦
## ការប្ដឹងតវ៉ា

**ប្រការ១៩._**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការផ្តល់លិខិតអនុញ្ញាតសាងសង់ មានសិទ្ធិប្តឹងតវ៉ាទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬទៅតុលាការតាមនីតិវិធីជាធរមាន។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**ប្រការ២០._**

លិខិតបទដ្ឋាននិងគោលការណ៍ណែនាំរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតសាងសង់ ដែលអនុវត្តមុនប្រកាសនេះចូលជាធរមាន ត្រូវមានអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋាននិងគោលការណ៍ណែនាំថ្មីមកជំនួស។

លិខិតអនុញ្ញាតសាងសង់ដែលបានផ្តល់ជូនម្ចាស់មុនប្រកាសនេះចូលជាធរមាន នៅបន្តសុពលភាពរហូតថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតសាងសង់នោះ។

**ប្រការ២១._**

ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ និងពាក្យស្នើសុំលិខិតបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ ដែលបានដាក់នៅច្រកចេញចូលតែមួយមុនប្រកាសនេះចូលជាធរមាន អគ្គនាយកដ្ឋានជំនាញនិងច្រកចេញចូលតែមួយ ត្រូវបន្តដំណើរការពិនិត្យនិងសម្រេចរហូតដល់ចប់នីតិវិធី។ ក្នុងករណីនេះ អគ្គនាយកដ្ឋានជំនាញ និងច្រកចេញចូលតែមួយ ត្រូវអនុវត្តគោលការណ៍ឬលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងប្រកាសនេះដែលផ្តល់ប្រយោជន៍ដល់ម្ចាស់សំណង់។

# ជំពូកទី៨
# អវសានប្បញ្ញត្តិ

**ប្រការ២២.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៣.**_

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

  **"ដើម្បីជូនជ្រាប"**
- ដូចប្រការ២៣ **"ដើម្បីអនុវត្ត"**
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃប្រកាសលេខ ០១៣ ដនស/ប្រ.ក/នី.ក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២២ ស្តីពី
បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

***គំរូទម្រង់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់***

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់**

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ ____________________ ភេទ _______ អាយុ _______ ឆ្នាំ សញ្ជាតិ _________
មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ ____________________ ផុតកំណត់ ______________
ជាតំណាងស្របច្បាប់របស់ ____________________________________________ (នាមករណ៍នីតិបុគ្គល)
មានទីស្នាក់ការ ផ្ទះ/អគារលេខ _______ ផ្លូវ ________ ភូមិ _________ ឃុំ/ សង្កាត់ _____________________
ក្រុង/ ស្រុក/ ខណ្ឌ __________ រាជធានី/ ខេត្ត __________ អ៊ីមែល _____________ លេខទូរស័ព្ទ _________

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កម្មវត្ថុ៖** សំណើសុំលិខិតអនុញ្ញាតសាងសង់ ____________________________________________
ស្ថិតនៅលើក្បាលដី/ ដីឡូត៍លេខ __________ ផ្លូវ _____ ភូមិ _______ ឃុំ/ សង្កាត់ _____________
ក្រុង/ ស្រុក/ ខណ្ឌ ___________________ រាជធានី/ ខេត្ត ______________________ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ខ្ញុំបាទ/ នាងខ្ញុំ មានបំណងសាងសង់ ______________________________________________ ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបចំនួន ________________ ម៉ែត្រក្រឡា នៅលើក្បាលដីដែលមាន ______________________ (ឯកសារបញ្ជាក់ការកាន់កាប់ដីស្របច្បាប់) លេខ ______________ ចុះថ្ងៃទី ______ ខែ ______ ឆ្នាំ២០ _____ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/ នាងខ្ញុំ។

ថ្ងៃ___________ ខែ ______ ឆ្នាំ ______ ស័ក ព.ស.២៥ _

ធ្វើនៅ ______________ ថ្ងៃទី ____ ខែ _______ ឆ្នាំ២០_______

ហត្ថលេខាឬស្នាមមេដៃស្តាំ គោត្តនាមនិងនាមរបស់ម្ចាស់សំណង់
ឬតំណាងស្របច្បាប់ និងត្រារបស់របស់នីតិបុគ្គល

ឧបសម្ព័ន្ធ២នៃប្រកាសលេខ ០១៣ ដនស/ប្រ.ក/និក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២២ ស្តីពីបែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

***គំរូទម្រង់សលាកបត្រក្បាលដី (ទម្រង់ក្រដាស A3)***

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់**
**និងសុរិយោដី** ____________

**លេខ:** ________ **ដ.ន.ស.ស** ______

# សលាកបត្រក្បាលដី

- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ________ ចុះថ្ងៃទី ____ ខែ ____ ឆ្នាំ២០____
- ទំហំដី: ________ ម៉ែត្រក្រឡា ប្រភេទដី: ________ រូបភាពប្រើប្រាស់ដី: ________ លក្ខណៈនៃការប្រើប្រាស់ដី: ________
- ទីតាំង: ផ្លូវ ________ ភូមិ ________ ឃុំ/សង្កាត់ ________ ក្រុង/ស្រុក/ខណ្ឌ ________ រាជធានី/ខេត្ត ________
- កម្មសិទ្ធិករនៃដី: ________
- ប្រភេទប្រើប្រាស់ដី:(ដីអាចសាងសង់បាន/ដីកម្រិតការសាងសង់) ________
- តំបន់ប្រើប្រាស់ដី:(តំបន់ពាណិជ្ជកម្ម/តំបន់លំនៅឋាន ___) ________
- ស្ថានភាពនៃសំណង់ក្នុងដីឡូត៍: ________
- ស្ថានភាពនៃសំណង់ជុំវិញទីតាំង: ________







| តារាងនិយាមកាក្បាលដី | | |
|---|---|---|
| ចំណុច | អាប់ស៊ីស | អ័រដោនេ |
| 1 | 488626.296 | 1270860.603 |
| 2 | 488640.337 | 1270829.394 |
| 3 | 488657.169 | 1270789.972 |
| 4 | 488620.645 | 1270761.805 |
| 5 | 488633.539 | 1270723.373 |
| 6 | 488581.602 | 1270700.616 |
| 7 | 488542.978 | 1270788.765 |
| 8 | 488556.081 | 1270794.506 |
| 9 | 488542.990 | 1270826.304 |

**កំណត់សម្គាល់**

- ព្រំដីកាន់កាប់ស្របច្បាប់
- អ័ក្សផ្លូវ

រូបថតបង្ហាញទីតាំងភូមិសាស្ត្រ

រូបថតបង្ហាញទីតាំងដីឡូត៍

ថ្ងៃ________ ខែ ____ ឆ្នាំ ____ ស័ក ព.ស.២៥__
________ ថ្ងៃទី ____ ខែ ____ ឆ្នាំ២០____
**វាស់វែងនិងគូរដោយ**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃ________ ខែ ____ ឆ្នាំ ____ ស័ក ព.ស.២៥__
________ ថ្ងៃទី ____ ខែ ____ ឆ្នាំ២០____
**ប្រធានការិយាល័យ** ________

បានឃើញ និងឯកភាព
ថ្ងៃ________ ខែ ____ ឆ្នាំ ____ ស័ក ព.ស.២៥__
________ ថ្ងៃទី ____ ខែ ____ ឆ្នាំ២០____
**ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់**
**និងសុរិយោដី** ________

ឧបសម្ព័ន្ធ៣នៃប្រកាសលេខ ០១៣ ដនសស/ប្រ.ក/នីក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២២ ស្តីពី បែបបទនិងបរិបទនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

*គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់សម្រាប់នីតិបុគ្គល*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**អគ្គនាយកដ្ឋានរដ្ឋបាល**
**ច្រកចេញចូលតែមួយ**

## តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់សម្រាប់នីតិបុគ្គល

គម្រោងសាងសង់ ________________ របស់ ________________________ (នាមករណ៍នីតិបុគ្គល)

តំណាងដោយ __________________________ ស្ថិតនៅលើក្បាលដី/ដីឡូត៍លេខ ______________

ផ្លូវ _______ ភូមិ ________ ឃុំ/ សង្កាត់ _______ ក្រុង/ ស្រុក/ ខណ្ឌ ________ រាជធានី/ ខេត្ត ________

| ល.រ. | រាយឈ្មោះឯកសារ | ចំនួនតម្រូវ | ចំនួនទទួល | ការខ្វះខាតឯកសារ និងភាពមិនត្រឹមត្រូវផ្នែកទម្រង់ |
|---|---|---|---|---|
| ១ | ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់(ច្បាប់ដើម) | ១ | | |
| ២ | ឯកសារបញ្ជាក់អត្តសញ្ញាណម្ចាស់សំណង់ | | | |
| | **សម្រាប់គ្រប់នីតិបុគ្គលទាំងអស់** | | | |
| | -អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់តំណាងស្របច្បាប់របស់នីតិបុគ្គល ឬតំណាងដែលទទួលសិទ្ធិ | ២ | | |
| | -លិខិតប្រគល់សិទ្ធិជាអ្នកតំណាងរបស់នីតិបុគ្គល ករណីបើមាន (ច្បាប់ដើម) | ១ | | |
| | **ករណីក្រសួង ស្ថាប័ន អង្គភាពរដ្ឋ** | | | |
| | -លិខិតឧទ្ទេសនាមតំណាងក្រសួង ស្ថាប័ន ឬអង្គភាព (ច្បាប់ដើម) | ១ | | |
| | **ករណីសហគ្រាសពាណិជ្ជកម្ម** | | | |
| | -វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន | ២ | | |
| | -លក្ខន្តិកៈក្រុមហ៊ុន | ២ | | |
| | **ករណីសមាគមឬអង្គការមិនមែនរដ្ឋាភិបាល** | | | |

| | | | | |
|---|---|---|---|---|
| | -លក្ខន្តិកៈនិងប្រកាសស្តីពីការចុះបញ្ជីសមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក(ថតចម្លង) ឬ<br>-អនុស្សរណៈរបស់អង្គការឬសមាគមមិនមែនរដ្ឋាភិបាលបរទេសនិងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ(ថតចម្លង) | ២ | | |
| | **ករណីនីតិបុគ្គលដទៃទៀត** | | | |
| | -ប្រកាសស្តីពីការចុះបញ្ជីនីតិបុគ្គលនោះចេញដោយស្ថាប័នពាក់ព័ន្ធ (ថតចម្លង) | ២ | | |
| ៣ | ឯកសារបញ្ជាក់ការកាន់កាប់ដីស្របច្បាប់ | | | |
| | -វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ | ២ | | |
| | -បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ(ថតចម្លង) ឬ | ២ | | |
| | -បណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី(ថតចម្លង) ឬ | ២ | | |
| | -វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច(ថតចម្លង) ឬ | ២ | | |
| | -វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង(ថតចម្លង) ឬ | ២ | | |
| | -វិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ(ថតចម្លង) ឬ | ២ | | |
| | -ភតិសន្យាអចលនវត្ថុ(ថតចម្លង) ឬ | ២ | | |
| | -ការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីម្ចាស់ដី ក្នុងករណីឯកសារបញ្ជាក់ការកាន់កាប់ដីស្របច្បាប់ ជាវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ ឬភតិសន្យាអចលនវត្ថុ(ច្បាប់ដើម) | ១ | | |
| | -គោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល(ថតចម្លង) | ២ | | |
| ៤ | សលាកបត្រក្បាលដី | ២ | | |
| ៥ | លិខិតបញ្ជាក់ព័តិមានសុរិយោដី (លើកលែងក្បាលដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ) | ២ | | |
| ៦ | ប្លង់ស្ថាបត្យកម្ម | ៥ | | |
| ៧ | សេចក្តីណែនាំបច្ចេកទេសផ្នែកស្ថាបត្យកម្ម | ២ | | |
| ៨ | របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម | ៥ | | |
| ៩ | លិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់ស្ថាបត្យកម្ម | ៥ | | |

| | | | | |
|---|---|---|---|---|
| ១០ | ប្លង់សម្រង់តាមការសាងសង់ជាក់ស្តែងផ្នែកស្ថាបត្យកម្ម (ករណីគម្រោងកែប្រែ) | ២ | | |
| ១១ | គោលការណ៍ផ្តល់ដោយក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ករណីបើមាន (ច្បាប់ដើម) | ១ | | |
| ១២ | លិខិតអនុញ្ញាតអភិវឌ្ឍដី (ករណីគម្រោងសាងសង់ជាគម្រោងអភិវឌ្ឍន៍អចលនវត្ថុ) | ២ | | |
| ១៣ | ប្លង់អភិវឌ្ឍដី (ករណីគម្រោងសាងសង់ជាគម្រោងអភិវឌ្ឍន៍អចលនវត្ថុ) | ២ | | |

គ្រប់គ្រាន់ ☐ មិនគ្រប់គ្រាន់ ☐ មិនត្រឹមត្រូវផ្នែកទម្រង់ ☐

សេចក្តីណែនាំរបស់ច្រកចេញចូលតែមួយ ក្នុងករណីសំណុំឯកសារមិនគ្រប់គ្រាន់និង/ឬមិនត្រឹមត្រូវផ្នែកទម្រង់៖

________________________________________

________________________________________

ថ្ងៃ__________ខែ ______ឆ្នាំ ______ស័ក ព.ស.២៥_

ធ្វើនៅ _____________ថ្ងៃទី _____ខែ _______ឆ្នាំ២០___

ឧបសម្ព័ន្ធ៤នៃប្រកាសលេខ ០១៣ ដនសស/ប្រ.ក/ន.ក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២២ ស្តីពីបែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

*គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់សម្រាប់រូបវន្តបុគ្គល*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**អគ្គនាយកដ្ឋានរដ្ឋបាល**
**ច្រកចេញចូលតែមួយ**

## តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់សម្រាប់រូបវន្តបុគ្គល

គម្រោងសាងសង់ ________________ របស់ ________________

(គោត្តនាមនិងនាមរបស់ម្ចាស់សំណង់) ស្ថិតនៅលើក្បាលដី/ដីឡូត៍លេខ ____________ ផ្លូវ __________

ភូមិ ________________ ឃុំ/សង្កាត់ ________ ក្រុង/ស្រុក/ខណ្ឌ ________ រាជធានី/ខេត្ត ________

| ល.រ. | រាយឈ្មោះឯកសារ | ចំនួនតម្រូវ | ចំនួនទទួល | ការខ្វះខាតឯកសារ និងភាពមិនត្រឹមត្រូវផ្នែកទម្រង់ |
|---|---|---|---|---|
| ១ | ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់(ច្បាប់ដើម) | ១ | | |
| ២ | ឯកសារបញ្ជាក់អត្តសញ្ញាណម្ចាស់សំណង់ | | | |
| | -អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន(ថតចម្លង) | ២ | | |
| | -សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត(ថតចម្លង) ឬ | ២ | | |
| | -សៀវភៅគ្រួសារ(ថតចម្លង) | ២ | | |
| ៣ | ឯកសារបញ្ជាក់ការកាន់កាប់ដីស្របច្បាប់ | | | |
| | -វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ | ២ | | |
| | -បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ(ថតចម្លង) ឬ | ២ | | |
| | -បណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី(ថតចម្លង) ឬ | ២ | | |
| | -វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច(ថតចម្លង) ឬ | ២ | | |
| | -វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង(ថតចម្លង) ឬ | ២ | | |
| | -វិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ(ថតចម្លង) ឬ | ២ | | |
| | -ភតិសន្យាអចលនវត្ថុ(ថតចម្លង) ឬ | ២ | | |

| | | | | |
|---|---|---|---|---|
| | -ការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីម្ចាស់ដី ក្នុងករណីឯកសារបញ្ជាក់ការកាន់កាប់ដីស្របច្បាប់ ជាវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ ឬភតិសន្យាអចលនវត្ថុ (ច្បាប់ដើម) | ១ | | |
| | -គោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល(ថតចម្លង) | ២ | | |
| ៤ | សលាកបត្រក្បាលដី | ២ | | |
| ៥ | លិខិតបញ្ជាក់ព័ត៌មានសុរិយោដី (លើកលែងក្បាលដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ) | ២ | | |
| ៦ | ប្លង់ស្ថាបត្យកម្ម | ៥ | | |
| ៧ | សេចក្តីណែនាំបច្ចេកទេសផ្នែកស្ថាបត្យកម្ម | ២ | | |
| ៨ | របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម | ៥ | | |
| ៩ | លិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់ស្ថាបត្យកម្ម | ៥ | | |
| ១០ | គោលការណ៍ផ្តល់ដោយក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ករណីបើមាន (ច្បាប់ដើម) | ១ | | |
| ១១ | ប្លង់សម្រង់តាមការសាងសង់ជាក់ស្តែងផ្នែកស្ថាបត្យកម្ម (ករណីគម្រោងកែប្រែ) | ២ | | |
| ១២ | លិខិតអនុញ្ញាតអភិវឌ្ឍដី (ករណីគម្រោងសាងសង់ជាគម្រោងអភិវឌ្ឍន៍អចលនវត្ថុ) | ២ | | |
| ១៣ | ប្លង់អភិវឌ្ឍដី (ករណីគម្រោងសាងសង់ជាគម្រោងជាអភិវឌ្ឍន៍អចលនវត្ថុ) | ២ | | |

គ្រប់គ្រាន់ ☐ មិនគ្រប់គ្រាន់ ☐ មិនត្រឹមត្រូវផ្នែកទម្រង់ ☐

សេចក្តីណែនាំរបស់ច្រកចេញចូលតែមួយ ក្នុងករណីសំណុំឯកសារមិនគ្រប់គ្រាន់និង/ឬមិនត្រឹមត្រូវផ្នែកទម្រង់៖

______________________________________________

______________________________________________

ថ្ងៃ__________ខែ ______ឆ្នាំ ______ស័ក ព.ស.២៥ _

ធ្វើនៅ ____________ថ្ងៃទី _____ខែ _______ឆ្នាំ២០ ___

ឧបសម្ព័ន្ធ៥នៃប្រកាសលេខ ០១៣ ដនស/ប្រ.ក/នី.ក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២២ ស្តីពី
បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

***គំរូទម្រង់លិខិតប្រគល់សិទ្ធិធ្វើជាអ្នកតំណាង***

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| រូបសញ្ញានិងនាមករណ៍របស់នីតិបុគ្គល |
|---|

## លិខិតប្រគល់សិទ្ធិ

ខ្ញុំបាទ/ នាងខ្ញុំ ________________ ជា ______________(តំណាងស្របច្បាប់របស់នីតិបុគ្គល) សូមប្រគល់សិទ្ធិជូនលោក/ លោកស្រី ________________ មានតួនាទីជា ____________________ ធ្វើជាអ្នកតំណាងឬភ្នាក់ងារតំណាងរបស់ __________________________(នាមករណ៍របស់នីតិបុគ្គល) ក្នុងការចុះហត្ថលេខាឬផ្តិតស្នាមមេដៃលើរាល់ឯកសារពាក់ព័ន្ធដើម្បីដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ______________________________________________________________ (ឈ្មោះគម្រោង)។

ហត្ថលេខាឬស្នាមមេដៃស្តាំរបស់អ្នកទទួលសិទ្ធិ

គោត្តនាមនិងនាម

ថ្ងៃ ........................ ខែ ........... ឆ្នាំ ....... ......ស័ក ព.ស.២៥ ...
ធ្វើនៅ ....................... ថ្ងៃទី .........ខែ ............ ឆ្នាំ២០ .........

ហត្ថលេខា គោត្តនាមនិងនាមរបស់តំណាងស្របច្បាប់
និងត្រារបស់នីតិបុគ្គល

ខ្ញុំសូមបញ្ជាក់ថា លោក/ លោកស្រី ________________ ដែលមានមុខងារជា______________ មានសិទ្ធិប្រគល់សិទ្ធិជូនលោក/ លោកស្រី __________________ មានតួនាទីជា ______________ ធ្វើជាអ្នកតំណាងឬភ្នាក់ងារតំណាងរបស់ ________________________________________ (នាមករណ៍របស់នីតិបុគ្គល) ស្របតាមលក្ខន្តិកៈរបស់________________(នីតិបុគ្គល) ពិតប្រាកដមែន។

______________________________
សារការី

ឧបសម្ព័ន្ធ៦នៃប្រកាសលេខ ០១៣ ដនស/ប្រ.ក/និ.ក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២២ ស្តីពីបែបបទ និងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

***គំរូទម្រង់លិខិតជូនដំណឹងស្តីពីការកែតម្រូវឬបំពេញបន្ថែមសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់***

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

អគ្គនាយកដ្ឋានរដ្ឋបាល

ច្រកចេញចូលតែមួយ

លេខ

ថ្ងៃ________ខែ______ឆ្នាំ______ស័ក ព.ស.២៥__

ធ្វើនៅ____________ថ្ងៃទី____ខែ_____ឆ្នាំ២០__

**ជម្រាបមក**

**លោក/លោកស្រី** ________________________ (ម្ចាស់សំណង់ឬតំណាងស្របច្បាប់របស់នីតិបុគ្គល)

**កម្មវត្ថុ៖** ការកែតម្រូវឬបំពេញបន្ថែមសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់

**យោង៖** -អនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់

-ប្រកាសលេខ_______________ចុះថ្ងៃទី_____ខែមករា ឆ្នាំ២០២២ស្តីពីបែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី________ខែ_______ឆ្នាំ២០___

-ដីកាបញ្ជូនលេខ________ចុះថ្ងៃទី______ខែ_____ឆ្នាំ២០__របស់អគ្គនាយកដ្ឋាន______

-ដីកាបញ្ជូនលេខ________ចុះថ្ងៃទី______ខែ_____ឆ្នាំ២០__របស់អគ្គនាយកដ្ឋាន______

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក/លោកស្រី ជ្រាបថាសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់របស់លោក/លោកស្រី មានភាពខ្វះចន្លោះ ឬមិនត្រឹមត្រូវ និង/ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម និង/ឬបទប្បញ្ញត្តិជាធរមានដទៃទៀតដូចខាងក្រោម៖

១- ______________________________________________

______________________________________________

២- ______________________________________________

______________________________________________

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រីចាត់ចែងកែតម្រូវនិង/ឬបំពេញបន្ថែមតាមការគួរ។

រយៈពេលនៃការកែតម្រូវនិង/ឬបំពេញបន្ថែមនេះ មិនរាប់បញ្ចូលក្នុងរយៈពេលនៃការពិនិត្យនិងសម្រេចផ្តល់លិខិតអនុញ្ញាតសាងសង់ឡើយ។ រយៈពេលនៃការពិនិត្យនិងសម្រេចផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវ

ចាប់រាប់ជាថ្មីឡើងវិញគិតចាប់ពីថ្ងៃច្រកចេញចូលតែមួយចេញបង្កាន់ដៃទទួលសំណុំឯកសារដែលបានកែតម្រូវ និង/ ឬបំពេញបន្ថែមនោះ។

សូមលោក/ លោកស្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ប្រធានច្រកចេញចូលតែមួយ**

ឧបសម្ព័ន្ធ៧នៃប្រកាសលេខ ០១៣ ដនស/ប.ក/នី.ក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២២ ស្តីពីបែបបទ និងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

***គំរូទម្រង់លិខិតជូនដំណឹងស្តីពីការបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់***

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ

ថ្ងៃ________ខែ ______ឆ្នាំ ______ស័ក ព.ស.២៥_

ធ្វើនៅ ___________ថ្ងៃទី ____ខែ _____ឆ្នាំ២០__

**ជម្រាបមក**

**លោក/លោកស្រី** _____________________(ម្ចាស់សំណង់ឬតំណាងស្របច្បាប់របស់នីតិបុគ្គល)

**កម្មវត្ថុ៖** ការបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់

**យោង៖** -អនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់

-ប្រកាសលេខ _________ចុះថ្ងៃទី _______ខែមករា ឆ្នាំ២០២២ ស្តីពីបែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី _______ខែ ______ឆ្នាំ២០ ___

-ចំណាររបស់ **ឯកឧត្តមរដ្ឋមន្ត្រី** ចុះថ្ងៃទី _______ខែ ______ឆ្នាំ២០ ___

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក/លោកស្រី ជ្រាបថាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់ជូនលោក/លោកស្រី ដោយមូលហេតុដូចខាងក្រោម៖

១- ____________________________________________________________

____________________________________________________________

២- ____________________________________________________________

____________________________________________________________

សូមលោក/ លោកស្រីមកទទួលយកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់របស់លោក/លោកស្រី ក្នុងរយៈពេល៣០( សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងនេះ។ ផុតរយៈពេលនេះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនរក្សាទុកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់របស់លោក/ លោកស្រីឡើយ។

សូមលោក/ លោកស្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

ឧបសម្ព័ន្ធ៨នៃប្រកាសលេខ ០១៣ ដនសស/ប្រ.ក/នី.ក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២២ ស្ដីពីបែបបទ និងបរិបថនៃការផ្ដល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

***គំរូទម្រង់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់***

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣❀៥

## ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ ____________ ភេទ ______ អាយុ ______ ឆ្នាំ សញ្ជាតិ ____________

មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ ____________ ផុតកំណត់ ____________

ជាតំណាងស្របច្បាប់របស់ ______________________________ (នាមករណ៍នីតិបុគ្គល)

មានទីស្នាក់ការ ផ្ទះ/អគារលេខ ______ ផ្លូវ _______ ភូមិ _________ ឃុំ/ សង្កាត់ ____________

ក្រុង/ស្រុក/ខណ្ឌ _________ រាជធានី/ ខេត្ត _________ អ៊ីមែល _________ លេខទូរស័ព្ទ ________

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**<u>កម្មវត្ថុ</u>៖** សំណើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់

**<u>យោង</u>៖** លិខិតអនុញ្ញាតសាងសង់លេខ _________ ថ្ងៃទី _____ ខែ ______ ឆ្នាំ២០ ___

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/ នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមានការចាំបាច់ ខ្ញុំបាទ/ នាងខ្ញុំគោរពស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ខាងលើ។

សូមគោរពជូនភ្ជាប់ឯកសារកែប្រែនៃសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ដូចខាងក្រោម (ករណីមានការកែប្រែ)៖

១- ______________________________

______________________________

២- ______________________________

______________________________

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាសម្រេចដោយសេចក្ដីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ __________ ខែ ___ ឆ្នាំ ______ ព.ស. ___

ធ្វើនៅ _______ ថ្ងៃទី _____ ខែ _____ ឆ្នាំ _______

ហត្ថលេខា គោត្តនាមនិងនាមរបស់ម្ចាស់សំណង់ ឬតំណាងស្របច្បាប់

និងត្រារបស់នីតិបុគ្គល

ឧបសម្ព័ន្ធ៩នៃប្រកាសលេខ ០១៧ ដនស/ប្រ.ក/នី.ក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២២ ស្តីពីបែបបទ និងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

*គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់សម្រាប់នីតិបុគ្គល*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អគ្គនាយកដ្ឋានរដ្ឋបាល

ច្រកចេញចូលតែមួយ

## តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់សម្រាប់នីតិបុគ្គល

គម្រោងសាងសង់ ________________ របស់ ____________________ (នាមករណ៍នីតិបុគ្គល)

តំណាងដោយ ________________________ ស្ថិតនៅលើក្បាលដី/ដីឡូត៍លេខ ________________

ផ្លូវ ________ ភូមិ ________ ឃុំ/សង្កាត់ ________ ក្រុង/ស្រុក/ខណ្ឌ ________ រាជធានី/ខេត្ត ________

| ល.រ. | រាយឈ្មោះឯកសារ | ចំនួនតម្រូវ | ចំនួនទទួល | ការខ្វះខាតឯកសារ និងភាពមិនត្រឹមត្រូវផ្នែកទម្រង់ |
|---|---|---|---|---|
| ១ | ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់(ច្បាប់ដើម) | ១ | | |
| ២ | ឯកសារបញ្ជាក់អត្តសញ្ញាណម្ចាស់សំណង់ ករណីមានការកែប្រែ | | | |
| | **សម្រាប់គ្រប់នីតិបុគ្គលទាំងអស់** | | | |
| | -អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់តំណាងស្របច្បាប់របស់នីតិបុគ្គល ឬតំណាងដែលទទួលសិទ្ធិ | ២ | | |
| | -លិខិតប្រគល់សិទ្ធិជាអ្នកតំណាងរបស់នីតិបុគ្គល ករណីបើមាន (ច្បាប់ដើម) | ១ | | |
| | **ករណីក្រសួង ស្ថាប័ន អង្គភាពរដ្ឋ** | | | |
| | -លិខិតឧទ្ទេសនាមតំណាងក្រសួង ស្ថាប័ន ឬអង្គភាព (ច្បាប់ដើម) | ១ | | |
| | **ករណីសហគ្រាសពាណិជ្ជកម្ម** | | | |
| | -វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន | ២ | | |
| | -លក្ខន្តិកៈក្រុមហ៊ុន | ២ | | |
| | **ករណីសមាគមឬអង្គការមិនមែនរដ្ឋាភិបាល** | | | |

| | | | | |
|---|---|---|---|---|
| | -លក្ខន្តិកៈនិងប្រកាសស្តីពីការចុះបញ្ជីសមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក(ថតចម្លង) ឬ<br>-អនុស្សរណៈរបស់អង្គការឬសមាគមមិនមែនរដ្ឋាភិបាលបរទេសនិងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ(ថតចម្លង) | ២ | | |
| | **ករណីនីតិបុគ្គលដទៃទៀត** | | | |
| | -ប្រកាសស្តីពីការចុះបញ្ជីនីតិបុគ្គលនោះចេញដោយស្ថាប័នពាក់ព័ន្ធ (ថតចម្លង) | ២ | | |
| ៣ | ឯកសារបញ្ជាក់ការកាន់កាប់ដីស្របច្បាប់ ករណីមានការកែប្រែ | | | |
| | -វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ | ២ | | |
| | -បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ(ថតចម្លង) ឬ | ២ | | |
| | -បណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី(ថតចម្លង) ឬ | ២ | | |
| | -វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច(ថតចម្លង) ឬ | ២ | | |
| | -វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង(ថតចម្លង) ឬ | ២ | | |
| | -វិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ(ថតចម្លង) ឬ | ២ | | |
| | -ភតិសន្យាអចលនវត្ថុ(ថតចម្លង) ឬ | ២ | | |
| | -ការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីម្ចាស់ដី ក្នុងករណីឯកសារបញ្ជាក់ការកាន់កាប់ដីស្របច្បាប់ ជាវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ ឬភតិសន្យាអចលនវត្ថុ (ច្បាប់ដើម) | ១ | | |
| | -គោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល(ថតចម្លង) | ២ | | |
| ៤ | សលាកបត្រក្បាលដី ករណីមានការកែប្រែ | ២ | | |
| ៥ | លិខិតបញ្ជាក់ព័ត៌មានសុរិយោដី (លើកលែងក្បាលដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ) ករណីមានការកែប្រែ | ២ | | |

គ្រប់គ្រាន់ ☐ មិនគ្រប់គ្រាន់ ☐ មិនត្រឹមត្រូវផ្នែកទម្រង់ ☐

សេចក្តីណែនាំរបស់ច្រកចេញចូលតែមួយ ក្នុងករណីសំណុំឯកសារមិនគ្រប់គ្រាន់និង/ឬមិនត្រឹមត្រូវផ្នែកទម្រង់៖

______________________________________________________________

______________________________________________________________

ថ្ងៃ__________ ខែ ______ ឆ្នាំ ______ ស័ក ព.ស.២៥ _

ធ្វើនៅ ____________ ថ្ងៃទី _____ ខែ _______ ឆ្នាំ២០ ___

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**អគ្គនាយកដ្ឋានរដ្ឋបាល**
**ច្រកចេញចូលតែមួយ**

## តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់សម្រាប់រូបវន្តបុគ្គល

គម្រោងសាងសង់ ______________________ របស់ ______________________

(គោត្តនាមនិងនាមរបស់ម្ចាស់សំណង់) ស្ថិតនៅលើក្បាលដី/ដីឡូត៍លេខ ____________ ផ្លូវ ________

ភូមិ __________ ឃុំ/សង្កាត់ __________ ក្រុង/ស្រុក/ខណ្ឌ __________ រាជធានី/ខេត្ត __________

| ល.រ. | រាយឈ្មោះឯកសារ | ចំនួនតម្រូវ | ចំនួនទទួល | ការខ្វះខាតឯកសារ និងភាពមិនត្រឹមត្រូវផ្នែកទម្រង់ |
|---|---|---|---|---|
| ១ | ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់(ច្បាប់ដើម) | ១ | | |
| ២ | ឯកសារបញ្ជាក់អត្តសញ្ញាណម្ចាស់សំណង់ ករណីមានការកែប្រែ | | | |
| | -អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន(ថតចម្លង) | ២ | | |
| | -សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត(ថតចម្លង) ឬ | ២ | | |
| | -សៀវភៅគ្រួសារ(ថតចម្លង) | ២ | | |
| ៣ | ឯកសារបញ្ជាក់ការកាន់កាប់ដីស្របច្បាប់ ករណីមានការកែប្រែ | | | |
| | -វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ | ២ | | |
| | -បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ(ថតចម្លង) ឬ | ២ | | |
| | -បណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី(ថតចម្លង) ឬ | ២ | | |
| | -វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច(ថតចម្លង) ឬ | ២ | | |
| | -វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង(ថតចម្លង) ឬ | ២ | | |
| | -វិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ(ថតចម្លង) ឬ | ២ | | |

| | | | | |
|---|---|---|---|---|
| | -ភតិសន្យាអចលនវត្ថុ(ថតចម្លង) ឬ | ២ | | |
| | -ការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីម្ចាស់ដី ក្នុងករណីឯកសារបញ្ជាក់ការកាន់កាប់ដីស្របច្បាប់ ជាវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ ឬភតិសន្យាអចលនវត្ថុ (ច្បាប់ដើម) | ១ | | |
| | -គោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល(ថតចម្លង) | ២ | | |
| ៤ | សលាកបត្រក្បាលដី ករណីមានការកែប្រែ | ២ | | |
| ៥ | លិខិតបញ្ជាក់ព័ត៌មានសុរិយោដី (លើកលែងក្បាលដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ) ករណីមានការកែប្រែ | ២ | | |

គ្រប់គ្រាន់ ☐ មិនគ្រប់គ្រាន់ ☐ មិនត្រឹមត្រូវផ្នែកទម្រង់ ☐

សេចក្តីណែនាំរបស់ច្រកចេញចូលតែមួយ ក្នុងករណីសំណុំឯកសារមិនគ្រប់គ្រាន់និង/ឬមិនត្រឹមត្រូវផ្នែកទម្រង់៖

________________________________________

________________________________________

ថ្ងៃ________ខែ _____ឆ្នាំ _____ស័ក ព.ស.២៥_

ធ្វើនៅ __________ថ្ងៃទី ____ ខែ ______ឆ្នាំ២០__